

# តម្លៃរបស់ មិន ជុន

ដោយ យែលី ហានសាយើរ
ផ្អែកទៅលើដំណើររឿងពិត

« *ព្រះយេស៊ូវជាសម្លាញ់យើង ។ . . . កុមារគួរស្រឡាញ់* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ៣៧* ) ។

មិន ជុនបានមើលពពកនៅខាងក្រៅបង្អួច ។ គាត់និយាយថា « វាមើលទៅទំនងជាមានភ្លៀងនៅថ្ងៃស្អែក » ។

លោកតាបានងាកមុខចេញពីការអានកាសែត ហើយសំឡឹងមើលទៅលើមេឃ ហើយងក់ក្បាល ។ វាគឺជាចុងរដូវក្តៅនៅក្នុងទីក្រុងសេអ៊ូល ប្រទេស កូរ៉េ ហើយរដូវវស្សាបានចាប់ផ្តើម ។

មិន ជុន បានរៀបចំឆត្រដាក់នៅក្បែរសម្លៀកបំពាក់សម្រាប់ពាក់ថ្ងៃអាទិត្យ ។ « ចៅគិតថា ថ្ងៃស្អែកពួកយើងគួរតែចេញដំណើរពីព្រលឹម » ។

លោកតាបានញញឹម ។ « គំនិតល្អ ។ យើងនឹងត្រូវដើរផ្លូវឆ្ងាយ ប្រសិនបើផ្លូវដែលទាបៗនោះលិចទឹក » ។

« តើលោកតាគិតថាអគារសាសនាចក្រនឹងគ្មានបញ្ហាអ្វីទេមែនទេ ? » មិន ជុន បានសួរ ។ ឆ្នាំមុននៅបន្ទប់ក្រោមដី បានលិចទឹកអំឡុងរដូវវស្សា ។

លោកតាបាននិយាយថា « មែនហើយ » ។

« ប៉ុន្តែវាមិនពិបាកឡើយដើម្បីអធិស្ឋាននោះ » ។

« ដូច្នោះចៅនឹងអធិស្ឋានសម្រាប់ព្រះវិហារនារាត្រីនេះ ។ ហើយយើងនឹងអាចធ្វើដំណើរទៅព្រះវិហារដោយសុវត្ថិភាព ។ *ចាល យ៉ា យ៉ូ* ( រាត្រីសួស្តី ) » ។ មិន ជុន បានឱនក្បាល ហើយចូលដេក ។

នៅពេលព្រឹកឡើង ពួកគេបានចេញពីផ្ទះពីព្រឹកព្រលឹម ។ មិន ជុន បានងើយមើលទៅពពកខ្មៅដែលគ្របដណ្តប់ពេញផ្ទៃមេឃ ។

លោកតាបាននិយាយថា « ចូរមានសេចក្តីជំនឿចុះ » ។

មិន ជុន បានដើរតាមលោកតាតាមជណ្តើរតូចដែលមានបង្កាន់ដៃនៅលើកូនភ្នំក្បែរផ្ទះរបស់ពួកគេ ។ ពួកគេបានឈប់សម្រាកនៅលើកំពូលនោះដើម្បីយកកម្លាំង ។ សំណើមដ៏ច្រើននៅក្នុងបរិយាកាសបានធ្វើឲ្យអាវ-សរបស់ពួកគេសើម ។

លោកតាបានលាដៃប៉ះតំណក់ទឹកភ្លៀងដំបូង ។ « តើចៅមានប៉ះទឹកភ្លៀងទេ ? ភ្លៀងចាប់ផ្តើមធ្លាក់ហើយ » ។

ពួកគេបានបាំងឆត្រ ។ នៅពេលពួកគេបានឡើងទៅដល់ជណ្តើរបន្ទាប់ ភ្លៀងបានធ្លាក់កាន់តែខ្លាំង ។ មិន ជុនបានមើលគ្រប់ជំហានដែលដើរកាត់ភ្លៀង ។ « អ៊ូយ ! » គាត់បានស្រែក នៅពេលគាត់រអិលដួល ហើយជង្គង់គាត់ដួលប៉ះដី ។

« តើចៅឈឺឬទេ ? » លោកតាបានសួរ ។ គាត់បានឈ្ងោកមើលស្នាមរហែកនៅលើខោរបស់មិន ជុន ។

មិន ជុន បាននិយាយដោយសំឡេងញ័រៗថា « វាគ្រាន់តែជាស្នាមរលាត់ទេ » ។

លោកតាបាននិយាយថា « យើងអាចដេរខោនេះនៅព្រះវិហារបាន » ។

មិន ជុន និង លោកតាបានបន្តឡើងជណ្តើរ ហើយបត់ទៅតាមផ្លូវខាងលើ ។

លោកតាបាននិយាយដោយបិតឆត្រវិញថា « ខ្យល់បក់ខ្លាំងណាស់នៅខាងលើនេះ » ។ មិន ជុន ក៏ពិបាកនឹងកាន់ឆត្ររបស់គាត់ដែរ ។ រំពេចនោះ ខ្យល់បានបក់យ៉ាងខ្លាំង ហើយបានធ្វើឲ្យឆត្ររលាត់ឡើង រហែកតាមថ្នេររបស់វា ។ មិន ជុន បានទម្លាក់ស្មាចុះដោយអស់សង្ឃឹម ។

លោកតាបានកាន់ឆត្រឲ្យគាត់ ។ « ចូលមកជ្រកជាមួយតាមក ។ យើងជិតដល់ព្រះវិហារហើយ » ។



មិន ជុន និង លោកតាបានជ្រកក្រោមឆត្រជាមួយគ្នា ប៉ុន្តែពួកគេនៅតែទទឹកភ្លៀងដែលបន្តធ្លាក់ឥតឈប់នោះ ។ នៅពេលពួកគេបានដើរជិតដល់ព្រះវិហារ មិន ជុន បានឮសំឡេងតន្ត្រី ។

« ពួកគេបានចាប់ផ្តើមប្រជុំហើយ ! » មិន ជុនបានរត់ទៅទ្វារមុខ ។ ក្រោយមកគាត់បានឃើញស្រមោលរបស់គាត់នៅក្នុងកញ្ចក់ ។ សក់គាត់ប្រែជាកន្ទ្រើងស្រក់ទឹកតក់ៗ ខោរបស់គាត់បានរហែក ហើយស្បែកជើងគាត់ប្រឡាក់ភក់ ។ គាត់បានថយចេញពីទ្វារ ហើយដើរចុះជណ្តើរវិញ ។

មិន ជុន និយាយដោយស្ទាក់ស្ទើរថា « ចៅ . . . ចៅមិនអាចចូលទៅបានទេ » ។

លោកតាបាននិយាយថា « ចូលទៅមិនអីទេចៅ » ។

« ប៉ុន្តែចៅកខ្វក់ ហើយសើមខ្លួនជោគ ! »

លោកតាបានមើលមុខ មិន ជុន ក្រោយមកបានមើលទៅឧបករណ៍វាស់ទឹកភ្លៀងដែលដាក់ព្យួរជាប់នឹងរបង ។

« វាងាយស្រួលដើម្បីវាស់កម្រិតទឹកភ្លៀង មិន ជុន ប៉ុន្តែតើយើងវាស់វែងខ្លួនរបស់យើងដោយរបៀបណា ? »

មិន ជុន បានព្រិចភ្នែកដាក់លោកតា ។

លោកតាបាននិយាយថា « ចៅឃើញថាស្បែកជើងចៅប្រឡាក់ភក់ ជង្គង់ចៅដួលដាច់រលាត់ សក់ចៅកន្ទ្រើងកន្ទ្រើង ហើយចៅគិតថា ចៅគ្មានតម្លៃសោះឬ » ។ « ប៉ុន្តែព្រះយេស៊ូវគ្រីស្ទមានរបៀបដ៏ប្រសើរដើម្បីផ្តល់តម្លៃឲ្យមនុស្ស ។ ទ្រង់ជ្រាបដឹងពីដួងចិត្តចៅ ហើយដឹងថាអ្វីដែលចៅកំពុងធ្វើគឺត្រឹមត្រូវ ។ ប្រសិនបើចៅផ្តល់តម្លៃខ្លួនឯងតាមរបៀបរបស់ទ្រង់នោះ ចៅនឹងឃើញពីតម្លៃដ៏ច្រើនលើសលុប » ។

មិន ជុនបានមើលឧបករណ៍វាស់ទឹកភ្លៀង ។ វាបន្តឡើងទៅៗនៅពេលភ្លៀងបន្តធ្លាក់ ។ គាត់បានគិតពីក្តីលំបាកយ៉ាងខ្លាំង ដែលគាត់បានពុះពារធ្វើដំណើរមកព្រះវិហារ និង ភាពកក់ក្តៅ ព្រមទាំងចិត្តរីករាយដែលគាត់បានមាននៅពេលគាត់បានមកដល់ព្រះវិហារ ។ គាត់បានគិតអំពីក្តីស្រឡាញ់ដ៏ធំធេងរបស់គាត់ចំពោះព្រះអង្គសង្គ្រោះ និង ក្តីស្រឡាញ់ដ៏ធំធេងរបស់ព្រះអង្គសង្គ្រោះមានចំពោះគាត់ ។

មិន ជុន បានឱបលោកតា ហើយពួកគេទាំងពីរនាក់បានដើរចូលទៅក្នុងព្រះវិហារ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ខូឡូរ៉ាដូ ស.រ.អា. ។*



**ចូរបន្តព្យាយាម**

« អ្វីដែលអស្ចារ្យអំពីដំណឹងល្អនោះ គឺថាយើងទទួលបានរង្វាន់ចំពោះ *ការព្យាយាម* ទោះជាយើងពុំបានជោគជ័យជានិច្ចក្តី » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់
« **Tomorrow the Lord Will Do Wonders among You** » *Liahona* ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ១២៥–១២៦ ។